ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកំពង់ធំ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៨ ចុះថ្ងៃទី ០៥
ខែ តុលា ឆ្នាំ ២០០២
សាលក្រម
លេខ ០៨ ចុះថ្ងៃទី ២៧
ខែ មករា ឆ្នាំ ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលជំនុំជំរះតុលាការខេត្តកំពង់ធំ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោកស្រី **ស៊ឹម សារ៉ះមុំ** ចៅក្រមតុលាការខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក **ឈុន ឈីមខន** ព្រះរាជអាជ្ញារងអមតុលាការខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី **អ៊ុំ សារ៉ាន់** ក្រឡាបញ្ជីតុលាការខេត្តកំពង់ធំ

**មេធាវី**

លោក **ឈិត សារិទ្ធ**

**ដើមីរឿងជំនុំជំរះ**

-ជនជាប់ចោទឈ្មោះ **ស ខ ម** ហៅ **ឆាន** ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃ ភូមិទូលដំណាក់ ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ របររកស៊ីលក់ទឹកកក ប្រពន្ធឈ្មោះ **ស ម** មានកូន ០១នាក់ ឪពុកឈ្មោះ **ឧ ម** (រ) ម្តាយឈ្មោះ **ស ង** (រ) ទោសពីមុន *គ្មាន* ។ ចាប់ខ្លួនថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ ។

ពីបទអំពើចោរកម្ម ប្រព្រឹត្តនៅភូមិទូលដំណាក់ ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ឈ ឃ** ភេទប្រុស អាយុ ៤៧ឆ្នាំ ទីលំនៅភូមិទូលដំណាក់ ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ប្តឹងថា កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ វេលាម៉ោង ១០យប់ មេឃកំពុងធ្លាក់ភ្លៀង ។ លុះពេលព្រឹក ខ្ញុំបានដឹងថា បាត់ជើងគ្រែ តាមដានទៅឃើញនៅផ្ទះ **ស ខម** ដែលលាក់ទុកក្រោមផ្ទះ ។

សំណូមពរសូមតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារជំងឺចិត្ត ២០ម៉ឺនរៀល ។

សាលក្រមព្រហ្មទណ្ឌលេខ ០៨ ចុះថ្ងៃទី ២៧-០១-២០០៣ បានចូលស្ថាពរ កាលពីថ្ងៃទី ២៨-០៣-២០០៣ រួចហើយ ដោយគ្មានគូភាគីណាចូលមកប្តឹងតាមកំណត់ច្បាប់ ។
កំពង់ធំ.ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥
**ចៅក្រមជំនុំជំរះ**

-ដីកាសន្និដ្ឋានស្ថាពរលេខ ៧៣៨ អ.ក/២០០២ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ។

-ដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១១៨២ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០២ របស់ចៅក្រមស៊ើបសួរ ។

-ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១១៨៣ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០២ របស់ប្រធានតុលាការខេត្តកំពង់ធំ ។

ឯរឿងហេតុមានដូចតទៅ : នៅយប់ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ឈ្មោះ **ឈ ឃ** បានបាត់ជើងគ្រែចំនួន ១៩សំរាប់ ដែលគាត់ទុកក្រោមផ្ទះ ពេលដឹងថា បាត់ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ មានការសង្ស័យលើឈ្មោះ **ស ទ ម** ដើរតាមដានឃើញដានជើងបាត់នៅផ្ទះ **ស ទ ម** ហើយធ្វើជាសួររកទិញអង្ករ ក៏បើកស្បូវក្រោមផ្ទះឃើញ ជើងគ្រែទាំង១៩សំរាប់នៅទីនោះមែន ក៏រាយការណ៍ជូនសមត្ថកិច្ចបានចាប់ខ្លួនតែម្តងរួម និង វត្ថុតាង ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ **ស ទ ម** បានឆ្លើយបញ្ជាក់ថា នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ម៉ោង ០៥ល្ងាចខ្ញុំទៅផ្ទះ **ជ** ពេលនោះមានគេទៅវត្តជាច្រើន ដោយចំវេនបិណ្ឌផង គេធ្វើនំបញ្ចុក ខ្ញុំហូបនឹងគេដែរ មានឈ្មោះ **ជ** ឈ្មោះ **ស** ឈ្មោះ **ម** ពេលម៉ោង ៨:៣០នាទី ខ្ញុំដើរមកផ្ទះវិញតែម្នាក់ឯង តែនៅតាមផ្លូវបានជួប **ឈ ឱ** បបួលចូលលេងផ្ទះគេមិនស្គាល់ខ្ញុំចូលលេងមួយសន្ទុះខ្ញុំចេញមកវិញ ឯឈ្មោះ **ឈ ឱ** មិនទាន់មកទេ ។ ពេលខ្ញុំមកដល់មេឃភ្លៀងខ្ញុំចុះមុជទឹកឃើញមានផ្លេកបន្ទោរ ឃើញមនុស្សលីបេទំលាក់នៅរបងផ្ទះខ្ញុំ ហើយដើរចេញ ខ្ញុំមិនស្គាល់គេទេ ខ្ញុំដើរឃ្លាំមើលមួយសន្ទុះវាមកវិញទៅយកបេ ពេលនោះមានផ្លេកបន្ទោរ វាឃើញខ្ញុំ វាទំលាក់បេចោលកណ្តាលផ្លូវរត់ទៅត្បូងបាត់ខ្ញុំរត់ទៅតាមក្រោយប្រហែល ៥០ម ទៅ៦០ម ត្រឡប់មកវិញ នៅកន្លែងវាទំលាក់នោះបានឃើញជើងគ្រែ ខ្ញុំក៏យកទៅទុកក្រោមផ្ទះមិនមាននរណាឃើញទេ ហើយខ្ញុំមិនដឹងថា យកពីណាមកទេ រួចខ្ញុំឡើងទៅដេកមិនបានប្រាប់ប្រពន្ធ និងបង ប្អូនជិតខាងទេ ពេលព្រឹកឡើងក៏ខ្ញុំមិនបានប្រាប់នរណាទៀតដែរ ឯបងឈ្មោះ **ឱ ម** គាត់បានដឹងបានសុំ ខ្ញុំយកទៅធ្វើគ្រែដេក បើម្ចាស់គេមិនមករក ។ សមត្ថកិច្ចបានចាប់ខ្លួនខ្ញុំថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ ម៉ោង ០៨ព្រឹកនេះឈ្មោះ **ឈ ឃ** បានទៅផ្ទះខ្ញុំឃើញជើងគ្រែទុកក្រោមផ្ទះ គាត់ថា របស់គាត់បានប្តឹងសមត្ថកិច្ចចាប់ខ្លួនខ្ញុំតែម្តង ។ ផ្ទះ **ឈ ឱ** នៅរំលងផ្ទះមួយនឹងផ្ទះខ្ញុំ ជើងគ្រែមាន១៩សំរាប់ សមត្ថកិច្ចបានរឹបអូសយកទៅហើយ ។ សូមតុលាការជួយរកយុត្តិធម៌ឱ្យខ្ញុំផង ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ **ឈ ឃ** បានបញ្ជាក់ថា ជាធម្មតាពេលខ្ញុំធ្វើជើងគ្រែរួច តែងយកទៅទុកក្រោមផ្ទះកូនឈ្មោះ **ន រ** ដែលស្ថិតនៅខាងលិចផ្ទះ ខ្ញុំមានជើងគ្រែចំនួន ១៩ជើង ។ បានទុកកន្លងមកមិនដែលបាត់ទេ ។ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ យប់នោះមានភ្លៀងធ្លាក់ រហូតដល់ភ្លឺខ្ញុំមិនបានពិនិត្យមើលជើងគ្រែទេ ពេលព្រឹកខ្ញុំទៅមើលបាត់ជើងគ្រែទាំង ១៩ ខ្ញុំបានតាមដានជើងឃើញស្លាមបាត់នៅផ្ទះ **ស ទ ម** ទើបមានការសង្ស័យលើឈ្មោះ **ស ទ ម** ជាអ្នកលួច ខ្ញុំបានអោយប្រពន្ធទៅមើលនៅក្រោមផ្ទះឈ្មោះ **ស ទ ម** ឃើញជើងគ្រែទាំង ១៩ ខ្ញុំបានទទួលយកវិញហើយគ្រប់ចំនួន ។

សំណូមពរសូមតុលាការផ្តន្ទាទោសជនល្មើស ទៅតាមច្បាប់មិនទាមទារជំងឺចិត្តអ្វីទេ ។

-សាក្សីបំភ្លឺឈ្មោះ **ស ញ** បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ ម៉ោង ០១រសៀលឈ្មោះ **រ អ** ជាប្អូនថ្លៃឈ្មោះ **ឈ** បានរាយការណ៍ឱ្យខ្ញុំបានដឹងថា ឈ្មោះ **ទ ម** បានលួចជើងគ្រែបងវា កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ អោយខ្ញុំទៅជួយពិនិត្យមើលវាទុកចោលនៅក្រោមផ្ទះរបស់វា ។ ខ្ញុំបានទៅមើលឃើញ



CamScanner

ជើងគ្រែប្រាកដមែន ពេលនោះនគរបាលបានទៅដល់ខ្ញុំបានប្រគល់ភារកិច្ចឱ្យគេធ្វើការ ។

-ជនរងគ្រោះឈ្មោះ ភ ន បានឆ្លើយបញ្ជាក់ថា ជាធម្មតាពេលនេះពេលនាងខ្ញុំធ្វើជើងគ្រែរួចតែងយកទៅទុកផ្ទះកូនឈ្មោះ ន រ នៅខាងលិចជាប់គ្នាមានជើងគ្រែចំនួន ១៩ជើង ។

នៅយប់ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ វេលាម៉ោង ០៨ និង ០៩យប់ មានភ្លៀងធ្លាក់យ៉ាងខ្លាំង ខ្ញុំមិនបានពិនិត្យមើលជើងគ្រែទេ លុះពេលព្រឹកបានទៅមើលឃើញ បាត់ជើងគ្រែអស់ទាំង ១៩គ្រឿង ខ្ញុំបានតាមដានជើងគ្រែឃើញបាត់ស្នាមនៅផ្ទះ ស ទ ម ខ្ញុំបានប្រាប់ឈ្មោះ រិត ឱ្យជួយស៊ើប ។ ខ្ញុំបានទៅផ្ទះ ស ទ ម ធ្វើជារកទិញស្បូវឯប្អូនទៅសួររកទិញអង្ករ ។ ឯ ស ទ ម ដេកអង្រឹងក្រោមផ្ទះ ។ ខ្ញុំបានឃើញជើងគ្រែ ដែលបាត់ទុកនៅទីនោះទាំងអស់ បានប្រាប់ប្អូនឱ្យទៅរាយការណ៍ប្រាប់ប៉ូលីស អោយខ្ញុំនៅចាំមើលជើងគ្រែ ខ្លាចវាយកចេញខាងក្រៅពេលប៉ូលីសមកចាប់បានរឹបអូសជើងគ្រែទាំង ១៩ ប្រគល់អោយខ្ញុំវិញ ឯ ស ទ ម បានសមត្ថកិច្ចឃាត់ខ្លួន ។

សូមតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់មិនទាមទារជំងឺចិត្តអ្វីទេ ។

-សាក្សីឈ្មោះ ន អ បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ វេលាម៉ោង ០៧ព្រឹក បងឈ្មោះ ល ន ជាប្រពន្ធ ឈ ឃ បានប្រាប់ខ្ញុំថា បាត់ជើងគ្រែ១៩គ្រឿង ដែលដាក់នៅផ្ទះកូនគាត់ឈ្មោះ ន រ ហើយឱ្យខ្ញុំជួយស៊ើបផ្ទះឈ្មោះ ស ទ ម ។ ពេលម៉ោង ០១រសៀលបានដើរទៅផ្ទះ ស ទ ម បាននិយាយ នឹងឈ្មោះ ខ ម សួរពីគាត់រកទិញអង្ករ ឬទេ ។ ឯបង ល ន គាត់ទៅផ្ទះ ស ទ ម បានឃើញថា កំពុងដេកអង្រឹងបងខ្ញុំនិយាយសួររកទិញស្បូវ រួចគាត់ចាប់បើកកណ្តប់ស្បូវឃើញជើងគ្រែរបស់គាត់ដែលបាត់ គាត់បានប្រាប់ខ្ញុំមកប្តឹងមេភូមិ និង ប៉ុស្តិ៍ ឯគាត់នៅចាំមើលដោយខ្លាចបណ្តោះវត្ថុតាង ។ នគរបាលបានទៅដល់បានដកហូតជើងគ្រែចំនួន ១៩គ្រឿងរួចចាប់ជនល្មើសមកតុលាការ ។

-សាក្សីឈ្មោះ ហ ឧ បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ នៅផ្ទះខ្ញុំមានរៀបធ្វើនំបញ្ចុកកាន់បិណ្ឌនៅវត្តចុងដូង មានអ្នកភូមិចូលរួមជាច្រើន ហើយបាន ស ទ ម ទៅហូបនំបញ្ចុកនឹងគេដែរ ពេលនោះម៉ោង ០៧យប់ហើយខ្ញុំមិនបានហៅវាមកទេ ។ ឈ្មោះ ស ទ ម ហូបរួចបានចេញបាត់មិនដឹងទៅណាទេ ដោយខ្ញុំមិនចាប់អារម្មណ៍ដោយរវល់ទៅបិណ្ឌ ។ ពេលហូបនោះមានឈ្មោះ ទ ដែរ ។ លុះក្រោយមកទើបដឹងថា ឈ្មោះ ស ទ ម ទៅលួចជើងគ្រែបងថ្លៃខ្ញុំក៏សមត្ថកិច្ចចាប់ខ្លួនតែម្តង ។

-សាក្សីឈ្មោះ ឡ ទ បានឆ្លើយបញ្ជាក់ថា ឈ្មោះ ស ទ ម ខ្ញុំបានស្គាល់នៅម៉ោង ៨យប់ថ្ងៃ ខែ មិនចាំ ផ្ទះបងឈ្មោះ ហ ឧ ធ្វើនំបញ្ចុកហូប ពីព្រោះគាត់កាន់បិណ្ឌ ពេលនោះឈ្មោះ ស ទ ម បានចូលរួមនឹងគេដែរ តែមិនមាននរណាហៅឱ្យហូបទេ វាហូបរួចមិនដឹងទៅណាទៀតទេ ។

-សាក្សីឈ្មោះ ខ ម បានឆ្លើយបញ្ជាក់ថា នៅពេលល្ងាចឈ្មោះ ស ទ ម ជាប្អូនថ្លៃបានប្រាប់ខ្ញុំទៅហូបនំបញ្ចុកនៅផ្ទះ ឧ វាទៅតែម្នាក់ឯងពេលមកវិញមិនដឹងម៉ោងប៉ុន្មានទេ ពេលព្រឹកឈ្មោះ រ ម្ចាស់អ្នកបាត់ជើងគ្រែបានទៅរើស្បូវក្រោមផ្ទះរបស់ ស ទ ម ខ្ញុំបានប្រាប់ថា បើស្គាល់ជើងគ្រែ ហើយយកទៅផ្ទះវិញចុះ ។ ខ្ញុំមិនបាននិយាយអោយទុកជើងគ្រែឱ្យខ្ញុំធ្វើគ្រែដេកនោះទេ ។ ពេលនោះសមត្ថកិច្ចមកដល់ថា ឈ្មោះ ស ទ ម លួចជើងគ្រែ ។

-របាយការណ៍លេខ ២៣៩ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ របស់នាយប៉ុស្តិ៍នគរបាលរដ្ឋបាលចុងដូង បានបញ្ជាក់ថា កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ វេលាម៉ោង ១០យប់ នៅភូមិទួលដំណាក់ ឃុំចុងដូង ស្រុកបារាយណ៍ បានទទួលពត៌មានពីជនរងគ្រោះឈ្មោះ ឈ ឃ ភេទប្រុស អាយុ ៤៣ឆ្នាំ នៅទួលដំណាក់ឃុំចុងដូង ។ ដោយថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ មានការសង្ស័យលើឈ្មោះ ស ទ ម នៅពេលបើកស្បូវមើលឃើញជើងគ្រែ



CamScanner

សមត្ថកិច្ចធ្វើការដកហូត និង ឃាត់ខ្លួនឈ្មោះ ស ទ ប ។ សកម្មភាព ស ទ ប នេះធ្លាប់ប្រព្រឹត្តបទល្មើសច្រើនលើកតែមិនបានចាប់ ។

-កំណត់ហេតុដកហូតវត្ថុតាង ប៉ុស្តិ៍រដ្ឋបាលឃុំចុងដូង ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ បានបញ្ជាក់ថា បានដកហូតជើងត្រៃចំនួន ១៩ នៅផ្ទះឈ្មោះ ស ទ ប ភេទប្រុស នៅភូមិទួលដំណាក់ ឃុំចុងដូង ដែលលួចពីផ្ទះ ឈ ឌ ។ ហើយជើងត្រៃមាន ១៩ នេះបានប្រគល់អោយឈ្មោះ ឈ ឌ វិញហើយ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទ ស ទ ប ចចេសរឹងរូសមិនព្រមសារភាពនូវកំហុសរបស់ខ្លួនវាថា ទៅយកជើងត្រៃពីជនម្នាក់មិនស្គាល់ឈ្មោះ ដែលទំលាក់ចោល ។ តែជាក់ស្តែងវាជាអ្នកទៅលួចផ្ទាល់អយ្យការរក្សាបទចោទដដែល សូមតុលាការសំរេចសេចក្តីទៅតាមច្បាប់ ។

-លោកមេធាវី បានធ្វើសេចក្តីសន្និដ្ឋានការពារថា ស ទ ប អង្គហេតុ កូនក្តីមិនបានទៅលួចផ្ទាល់ទេ ព្រោះការយកជើងត្រៃ ១៩ ដាក់ក្រោមផ្ទះមានស្បូវគ្របពីលើ បើការលួចមែន នឹងយកទៅលាក់ទុកនៅទីឆ្ងាយពីផ្ទះ ។

សូមតុលាការពិចារណាលើមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សុំតុលាការព្យួរទោស ដោយកូនក្តីមានជំងឺគ្រុនចាញ់ផងតាមជាក់ស្តែង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

## បានពិនិត្យសំណុំរឿងចប់សព្វគ្រប់
## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា យប់ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ឈ្មោះ ស ទ ប បានទៅលួចជើងត្រៃមាន ១៩ របស់ឈ្មោះ ឈ ឃ ដែលទុកនៅក្រោមផ្ទះឈ្មោះ ន ជាកូន ។

-យល់ឃើញថា ឈ្មោះ ស ទ ប ហៅ ធាន បានលួចយកជើងត្រៃបាន ១៩ ហើយយកមកលាក់ទុកក្រោមផ្ទះរបស់ខ្លួនយកស្បូវមកគ្រប ។

-យល់ឃើញ ឈ្មោះ ស ទ ប ហៅ ធាន មានចេតនាយកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន តែចចេសរឹងរូសមិនព្រមសារភាពនូវកំហុសរបស់ខ្លួន ។

-យល់ឃើញថា តំណាងអយ្យការរក្សាបទចោទដដែល សូមតុលាការសំរេចសេចក្តីទៅតាមច្បាប់ ។

-យល់ឃើញថា លោកមេធាវីបានធ្វើសន្និដ្ឋានការពារថា កូនក្តីខ្ញុំមិនបានលួចទេ តែសុំឱ្យតុលាការពិចារណាទៅតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង សុំតុលាការព្យួរទោសកូនក្តីនេះផង ។

-ដើមបណ្តឹងរដ្ឋប្បវេណី សុំអោយតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់មិនទាមទារសំណង នឹងជំងឺចិត្តអ្វីទេ ។

-ឈ្មោះ ស ទ ប ហៅ ធាន ល្មើសនឹងមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី



CamScanner

១-ផ្តន្ទាទោសឈ្មោះ ស ទ ប ហៅ ឆន ដាក់ពន្ធនាគារកំណត់ ១៨ខែ ពីបទ អំពើចោរកម្ម ប្រព្រឹត្ត នៅភូមិទួលដំណាក់ ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ តាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ទោសខាងលើនេះគិតតាំងពីថ្ងៃចាប់ខ្លួនបាន ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០២ ។

២-វត្ថុតាងមានជើងគ្រែ ១៩ ប្រគល់ឱ្យឈ្មោះ ឈ ឃ ជាម្ចាស់វិញ ។ ជើងគ្រែ ១៩ នេះឈ្មោះ ឈ ឃ បានទទួលរួចហើយ ។

២-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ មេធាវី ដើមបណ្តឹង បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
ស៊ីម សារ៉ាម៉ី